**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តរតនគិរី**
**គណៈកម្មាធិការលទ្ធកម្មខេត្ត**
លេខ : ០១២/១៩...ស.ជ.ណ

ថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅខេត្តរតនគិរី ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

**ការអញ្ជើញចូលរួមដេញថ្លៃការងារស្ថាបនាផ្លូវក្រាលកៅស៊ូ DBST លើកំណាត់ផ្លូវលេខ ៥៤២ , លេខ ៥៤៤ និងលេខ ៧៤ ប្រវែង ៩៤៧ម៉ែត្រ ទទឹង ០៧ម៉ែត្រ និងស្ថាបនាលូមូល បេតុងអាមេមុខកាត់ ០.៨ម៉ែត្រ តាមបណ្តោយផ្លូវលេខ ៧០ និងលេខ ៥៤៤ ប្រវែង ១.៥៧២ម៉ែត្រ ស្ថិតក្នុងភូមិថ្មី ភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ជូនរដ្ឋបាលខេត្តរតនគិរី**

រដ្ឋបាលខេត្តរតនគិរី សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា រដ្ឋបាលខេត្តរតនគិរី នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារស្ថាបនាផ្លូវក្រាលកៅស៊ូ DBST លើកំណាត់ផ្លូវលេខ ៥៤២ , លេខ ៥៤៤ និងលេខ ៧៤ ប្រវែង ៩៤៧ម៉ែត្រ ទទឹង ០៧ម៉ែត្រ និងស្ថាបនាលូមូលបេតុងអាមេមុខកាត់ ០.៨ម៉ែត្រ តាមបណ្តោយផ្លូវលេខ ៧០ និងលេខ ៥៤៤ ប្រវែង ១.៥៧២ម៉ែត្រ ស្ថិតក្នុងភូមិថ្មី ភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ជូនរដ្ឋបាលខេត្តរតនគិរី ។

រដ្ឋបាលខេត្តរតនគិរី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តរតនគិរី ដែលមានអាសយដ្ឋាន ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ចាប់ពីថ្ងៃទី ..០៤.... ខែ សីហា.....ឆ្នាំ ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៦១ ៣៣ ៧៧ ៩៩ ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មខេត្ត យ៉ាងយូរបំផុតត្រឹម ថ្ងៃទី...០៣..... ខែ..កញ្ញា.........ឆ្នាំ២០១៩ វេលាម៉ោង ...០៨:៣០..........។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨:៣០. ថ្ងៃទី ..០៣..... ខែ ..កញ្ញា.......... ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**អភិបាលរងខេត្ត និងជា**
**អនុប្រធានគណៈកម្មាធិការលទ្ធកម្មខេត្ត**

**មួង_ប៉ាច**

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ